# SIREN: ការវិភាគករណី

## បណ្តាញព័ត៌មានឆ្លើយតបជាយុទ្ធសាស្ត្រ

## គម្រោងអន្តរភ្នាក់ងារសហប្រជាជាតិស្តីពីការជួញដូរមនុស្ស (UNIAP): ដំណាក់កាលទី ៣

**បាងកក ប្រទេសថៃ**

ខែមិថុនា ឆ្នាំ ២០០៧

## សេចក្តីណែនាំស្តីពីបណ្តាញព័ត៌មានឆ្លើយតបជាយុទ្ធសាស្ត្រ (SIREN)

### តើអ្វីជាបណ្តាញព័ត៌មានឆ្លើយតបជាយុទ្ធសាស្ត្រ (SIREN) ?

**បណ្តាញព័ត៌មានឆ្លើយតបជាយុទ្ធសាស្ត្រ** (SIREN) គឺជាគំនិតផ្តួចផ្តើមថ្មីដែលទ្រទ្រង់ដោយអង្គការ UNIAP ដែលមានបំណងផ្តល់ទិន្នន័យ និងការវិភាគទៅលើបញ្ហាថ្មីៗ ទាក់ទិននឹងបញ្ហានៃការជួញដូរមនុស្ស ។ **បណ្តាញព័ត៌មានឆ្លើយតបជាយុទ្ធសាស្ត្រ** សំដៅលើអ្នកពាក់ព័ន្ធសំខាន់ៗ នៅក្នុងមហាអនុតំបន់ទន្លេមេគង្គ ទាំងក្នុងរដ្ឋាភិបាលនិងក្រៅរដ្ឋាភិបាល ដើម្បីឱ្យគេដឹងយកចិត្តទុកដាក់ និងធ្វើសកម្មភាពលើបញ្ហាជាគោលដៅ ។




SIREN មានបំណងផ្តល់ព័ត៌មាន ដល់ផ្នែកប្រឆាំងការជួញដូរមនុស្សតាមលក្ខណៈផ្សេងៗ ដូចជា របាយការណ៍ ផែនទី ទិន្នន័យ និង វេទិការពិភាក្សា ។ ការស្រាវជ្រាវ ការពិនិត្យ ផ្ទៀងផ្ទាត់ និងការវិភាគនឹង ធ្វើនៅតំបន់គោលដៅ ដោយអង្គការនៅតាមសហគមន៍ ទីភ្នាក់ ងារជាតិនិងអន្តរជាតិ និង UNIAP ផ្ទាល់ផងដែរ ។ គោលដៅគឺពាំនាំចំណេះដឹងពិតប្រាកដ និងបរិបទស្តីពីបញ្ហាអាទិភាពពិតប្រាកដ ពីថ្នាក់មូលដ្ឋានទៅ ថ្នាក់ជាតិនិងថ្នាក់តំបន់ និងពីថ្នាក់ជាតិនិងតំបន់ ទៅថ្នាក់មូលដ្ឋានវិញ ។

## តើ អ្វីជា SIREN .....ហើយតើអ្វីមិនមែនជា SIREN?

SIREN មិនមែនជាការស្រាវជ្រាវស៊ីជំរៅធំដុំទេ ហើយក៏មិនមែនជាការតស៊ូមតិឬការវាយតម្លៃរហ័សដែលធ្វើតែម្តងហើយនោះទេ ។ SIREN គឺជាការងារតាមមូលដ្ឋាន ការវិភាគ និងការពិភាក្សាជាក្រុមស្តីពីបញ្ហាសំខាន់ឬបញ្ហាខ្វះចន្លោះក្នុងការប្រឆាំងនឹងការជួញដូរមនុស្ស ។ បញ្ហាដែលលើកឡើងគឺជាបញ្ហាដែលត្រូវបានកំណត់ថា ជាអាទិភាពខ្ពស់ ដោយអ្នកពាក់ព័ន្ធនៅលំដាប់ថ្នាក់តំបន់ ថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន ដោយសារព័ត៌មានបានមកពីប្រភពដែលនៅជិតបំផុតទៅនឹងសកម្មភាពកើតឡើង ។ ដូច្នេះ របាការណ៍ ផែនទី និងការពិភាក្សារបស់SIREN មានបំណងបំពេញបន្ថែមការងារស្រាវជ្រាវ និងវិភាគដែលមានស្រាប់ ដោយធ្វើការសន្និដ្ឋាន និងវិភាគព័ត៌មានអោយបានត្រឹមត្រូវ ដើម្បីជំរុញសកម្មភាពសមស្របមួយក្នុងការធ្វើអន្តរាគមន៍ ។

## *តើហេតុអ្វីក៏ UNIAP បង្កើត SIREN?*

ដំណាក់កាលទី៣ របស់ UNIAP បានចាប់ផ្តើមនៅចុងឆ្នាំ២០០៦ ដោយមានអាណត្តិ ដែលគាំទ្រដោយអង្គការរដ្ឋាភិបាល មិនមែនរដ្ឋាភិបាលនិងទីភ្នាក់ងាររបស់សហប្រជាជាតិ ដើម្បីៈ

- សម្របសម្រួលការកំណត់បែងចែកការប្រើប្រាស់និងដៅធនធានសំរាប់ប្រឆាំងនឹងការជួញដូរ ដោយធ្វើយ៉ាងឱ្យអ្នកដែលរៀបចំនិងអនុវត្តកិច្ចអន្តរាគមន៍ប្រឆាំងនឹងការជួញដូរទទួលបានព័ត៌មានថ្មីៗ ការវិភាគ និងបទពិសោធន៍ដែលទទួលបាន និង
- បន្តដើរតួនាទីជម្រុញការឆ្លើយតបប្រឆាំងនឹងការជួញដូរ ដោយកំណត់ និងគាំទ្រគម្រោងពិសេសៗ ដើម្បីដោះស្រាយបញ្ហា និងឱកាសថ្មីៗ ។

នេះជាតួនាទីក្នុងការផ្តល់សេវា ដោយពង្រឹងបន្ថែមលើតួនាទីចែករំលែកព័ត៌មានដែល UNIAP មានតាំងពីឆ្នាំ២០០០មក ដោយធ្វើការជាមួយនឹងរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធនៅតាមសហគមន៍ដើម្បីរកមើលចន្លោះខ្វះខាតផ្នែកចំណេះដឹង និងរិះរកវិធីដើម្បីធ្វើការកែលម្អចំណេះដឹងនិងទិន្នន័យ តាមរយៈបទពិសោធន៍ ហើយបញ្ជូនពតិមានទៅកាន់ភ្នាក់ងារអន្តរាគមន៍ប្រឆាំងនឹងការជួញដូរទាំងអស់ ។

UNIAP មានភាពសក្តិសមបំផុតក្នុងការធ្វើការងារនេះ ដោយធ្វើជាស្ពានភ្ជាប់គ្នារវាងរដ្ឋាភិបាលនៅក្នុងមហាអនុតំបន់ទន្លេមេគង្គ និងអង្គការក្រៅរដ្ឋាភិបាលជាដៃគូរដែលមានការពាក់ព័ន្ធក្នុងផ្នែកប្រឆាំង

នឹងការជួញដូរមនុស្ស ។ ដោយទទួលបានផលប្រយោជន៍ពីទំនាក់ទំនងដ៏រឹងមាំនេះ និងការប្តេជ្ញាចិត្ត ក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្សនៅក្នុងមហាអនុតំបន់មេគង្គ SIREN ចង្អុលបង្ហាញដល់ភ្នាក់ងារ ប្រឆាំងការជួញដូរមនុស្ស ដើម្បីមានការយកចិត្តទុកដាក់និងធ្វើអន្តរាគមន៍ចំពោះតំបន់មួយចំនួន ដែលពុំទាន់ទទួលបានធ្វើអន្តរាគមន៍នៅឡើយ ឬ យ៉ាងហោចណាស់ក៏មានអន្តរាគមន៍យ៉ាងសមរម្យមួយ ។ លើសពីនេះទៀត SIREN ឆ្លើយតបទៅនឹងតម្រូវការទូទៅមួយដើម្បីឱ្យមានអន្តរាគមន៍ផ្អែកទៅលើការសិក្សាស្រាវជ្រាវ និងស្វែងរកគណនីយ្យភាព និងតម្លាភាពក្នុងផ្នែកមួយនេះ ។ ការបំភ្លឺលើផ្នែកដែលត្រូវការការយកចិត្តទុកដាក់និងសកម្មភាពថែមទៀត គឺជាវិធីនៃការត្រួតពិនិត្យ និងវាយតម្លៃថាតើការឆ្លើយតបប្រឆាំងនឹងការជួញដូរកំពុងតែដើរទៅតាមទិសណា និងថាតើការឆ្លើយតបនេះគួរធ្វើដំណើរឆ្ពោះទៅទិសណា ។

## តើលទ្ធផលរំពឹងទុកនៃ SIREN មានអ្វីខ្លះ – ហើយផ្តោតទៅលើនរណា?

បំណងរបស់ SIREN មានលក្ខណៈឆ្លើយតប និងអាចទុកចិត្តបាន ដោយផ្តល់ជាវេទិកាសម្រាប់ការផ្លាស់ប្តូរព័ត៌មាន និងការវិភាគយោងតាមប្រភពផ្សេងៗ តាមលក្ខណៈសាមញ្ញ និងងាយយល់ សម្រាប់អ្នកដែលត្រូវការព័ត៌មាននេះ ដើម្បីរៀបចំកម្មវិធីអោយមានប្រសិទ្ធិភាព ផ្តន្ទាទោសជនល្មើស ឬតាក់តែង គោលនយោបាយ ដូចជា:

- របាយការណ៍បែបវិភាគដែលបានមកពីអង្គការនៅតាមមូលដ្ឋាន
- ការវិភាគលើការស្រាវជ្រាវបញ្ហាសំខាន់ថ្មីៗ
- ធ្វើវិភាគលើករណី
- ទិន្នន័យដំបូងៗបូករួមជាមួយនឹងទិន្នន័យដែលត្រូវបានពិនិត្យផ្ទៀងផ្ទាត់រួម ដែលបានមកពីប្រភពដែលគួរអោយទុកចិត្តបាន
- ផែនទីអន្តរាគមន៍ ផែនទីបង្ហាញពីទីកន្លែងមានបញ្ហា និងឧបករណ៍ដទៃទៀត សម្រាប់ធ្វើផែនការជាអន្តរភ្នាក់ងារ
- ការពិភាក្សា និងវេទិកាពិភាក្សាដេញដោល ដើម្បីយល់ស៊ីជម្រៅបញ្ហាបន្ទាន់ពាក់ព័ន្ធដទៃទៀត ។

អាស្រ័យលើបញ្ហា អ្នកអានរបស់យើង អាចជាអង្គការនៅតាមសហគមន៍ទីភ្នាក់ងារអន្តរជាតិ (ទាំងរដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាល) ម្ចាស់ជំនួយ អ្នកតាក់តែងគោលនយោបាយ នគរបាល មេធាវី និងអ្នកផ្សេងទៀត មកពីផ្នែកយុត្តិធម៌ព្រហ្មទណ្ឌ និងផ្នែកអប់រំសិក្សា ។

ផ្នែកសំខាន់បំផុតរបស់ SIREN គឺបណ្តាញយុទ្ធសាស្ត្រ-បណ្តាញព័ត៌មានឆ្លើយតបជាយុទ្ធសាស្ត្រ ដែលហៅកាត់ថា SIREN ។ ដូច្នេះ មិនថានៅលើក្រដាសឬនៅលើតុពិភាក្សាទេ មួយភាគធំនៃ SIREN ត្រូវបានជម្រុញដោយ និងទទួលព័ត៌មានពីអង្គការដែលមានបរិបទ និងព័ត៌មានថ្មីៗ និងត្រឹមត្រូវសម្រាប់ចែករំលែក (ដោយសុវត្ថិភាព និងដោយអនាមិក ប្រសិនបើចាំបាច់) រួមជាមួយនឹងអង្គការដែលអាចជួយក្នុងការកំណត់វិធីសាស្ត្រហ្មត់ចត់ និងគ្រប់គ្រងលើគុណភាព រួមជាមួយនឹងអ្នកដែលអាចផ្តល់ទស្សនៈយល់ឃើញសំខាន់ផ្សេងៗទៀត ដូចជាគោលនយោបាយ ការអនុវត្តន៏ច្បាប់ ឬការគ្រប់គ្រងកម្មវិធីអន្តរាគមន៏ ។

វត្ថុបំណងសំខាន់របស់ UNIAP គឺផ្តល់វេទិការ ជំនួយបច្ចេកទេស ការចងជាបណ្តាញនិងយន្តការផ្សព្វផ្សាយសម្រាប់អង្គការ និងទីភ្នាក់ងារ ដើម្បីចែករំលែកនូវចំណេះដឹង រៀនសូត្រពីគ្នា និងធ្វើការផ្សារភ្ជាប់ទំនាក់ទំនងគ្នា ដើម្បីផ្តួចផ្តើម និងកែលម្អសកម្មភាពប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស ។ ដូច្នេះ លទ្ធផលការងាររបស់ SIREN មិនមែនសុទ្ធតែឆ្លុះបញ្ចាំងពីទស្សនៈ ឬ គោលជំហររបស់ UNIAP ទេ ។

**តើយើងម្នាក់ៗ ឬ អង្គការនីមួយៗរៀនសូត្របន្ថែមអំពី ឬរួមចំណែកដល់ SIREN យ៉ាងដូចម្តេច?**

តើអ្នកជានិស្សិត អង្គការ ឬភ្នាក់ងារដែលចង់ស្វែងយល់ពីលទ្ធភាពរួមចំណែកដល់ការងារ របស់ SIREN ឬ ផ្តើមការពិភាក្សា ឬ វេទិកាពិភាក្សាដេញដោលឬទេ? សូមទាក់ទងលោក Paul Buckley ដែលធ្វើ ការក្នុង UNIAP តាមអាស័យដ្ឋាន paul.buckley@undp.org ដើម្បីធ្វើការស្នើសុំយោបល់លើប្រធានបទណាមួយ ឬមតិយោបល់ ឬដើម្បីពិភាក្សាពីការចូលរួម ចំណែកដល់ SIREN ។

**ដើម្បីយល់ដឹងបន្ថែមពី UNIAP និងមើលរបាយការណ៏ថ្មីៗរបស់** SIREN**សូមបើកគេហទំព័រ**

**www.no-trafficking.org ។**

**SIREN គឺជាគំនិតផ្តួចផ្តើមមួយ ដែលគាំទ្រដោយ :**

**គម្រោងអន្តរភ្នាក់ងារសហប្រជាជាតិស្តីពីការជួញដូរមនុស្ស**

**ការិយាល័យគ្រប់គ្រងគម្រោងថ្នាក់តំបន់ (UNIAP/PMO)**
**7th Floor, Block B**
**Rajadamnern Nok Avenue, Bangkok 10200**
**THAILAND**

**www.no-trafficking.org**